មេរៀនទី១០

# ការប្រព្រឹត្តដែលព្រះស្អប់

***តើអ្នកគួរយល់យ៉ាងណាអំពីអ្វីដែលព្រះមានបន្ទូលថាជារបស់អាក្រក់នោះ? (១)***

***តើការរួមដំណេកបែបយ៉ាងណាដែលជាការខុស? (២)***

***តើគ្រីស្ទានគួរមានទស្សនៈយ៉ាងណាអំពីការកុហក? (៣) ការលេងល្បែង? (៣) ការលួច? (៣) អំពើឃោរឃៅ? (៤) មន្តអាគម? (៥) ការស្រវឹង (៦)***

***តើគេអាចដោះខ្លួនចេញពីការប្រព្រឹត្តអាក្រក់យ៉ាងដូចម្តេច? (៧)***

១. អ្នកបំរើនៃព្រះស្រឡាញ់អ្វីដែលជាការល្អ ។ ប៉ុន្តែ ពួកគេក៏ត្រូវតែរៀនស្អប់អ្វីដែលជាការអាក្រក់ដែរ ។ (ទំនុកដំកើង ៩៧:១០) នេះមានន័យថាត្រូវជៀសវាងការប្រព្រឹត្តខ្លះដែលព្រះទ្រង់ស្អប់ ។ តើការប្រព្រឹត្តទាំងនោះមានអ្វីខ្លះ?

២. *ការសហាយស្មន់៖* ការរួមដំណេកមុនពេលរៀបការ ការផិតក្បត់ ការសេពមេថុននឹងសត្វ ការស្មន់ និងការប្រតិព័ទ្ធមនុស្សភេទដូចគ្នា គឺសុទ្ធតែជាអំពើបាបធ្ងន់ធ្ងរប្រឆាំងនឹងព្រះ ។ (លេវីវិន័យ ១៨:៦; រ៉ូម ១:២៦, ២៧; កូរិនថូសទី១ ៦:៩, ១០) បើសិនជាគូប្រុសស្រីមិនបានរៀបការ តែរស់នៅជាមួយគ្នា នោះពួកគេគួរតែទៅនៅផ្សេងពីគ្នា ឬបើមិនដូច្នោះទេ ពួកគេគួររៀបអាពាហ៍ពិពាហ៍ឲ្យត្រឹមត្រូវតាមច្បាប់ ។ —ហេព្រើរ ១៣:៤

៣. *ការកុហក ការលេងល្បែង ការលួច៖* ព្រះយេហូវ៉ាទ្រង់មិនអាចមានបន្ទូលកុហកទេ ។ (ទីតុស ១:២) បុគ្គលណាដែលចង់ឲ្យទ្រង់យល់ព្រមទទួលស្គាល់ត្រូវតែជៀសពីការកុហក ។ (សុភាសិត ៦:១៦-១៩; កូល៉ុស ៣:៩, ១០) ការលេងល្បែងគ្រប់បែបយ៉ាងគឺប្រកបទៅដោយសេចក្តីលោភលន់ ។ ដូច្នេះ គ្រីស្ទានឥតរួមចំណែកក្នុងការលេងល្បែងគ្រប់បែបយ៉ាងទាំងអស់ ដូចជាលេងឆ្នោត ល្បែងប្រណាំងសេះ និងល្បែងប៊ីងហ្គោ ។ (អេភេសូរ ៥:៣-៥) ហើយគ្រីស្ទានក៏មិនលួច



***ព្រះទ្រង់ស្អប់ការស្រវឹងស្រា ការលួច ការលេងល្បែង និងអំពើឃោរឃៅ***

ដែរ ។ ពួកគេមិនទិញរបស់ដែលខ្លួនដឹងថាបានលួចពីអ្នកដទៃមក ឬយករបស់អ្វីដោយគ្មានសេចក្ដីអនុញ្ញាតនោះឡើយ ។—និក្ខមនំ ២០:១៥; អេភេសូរ ៤:២៨

៤. *កំហឹង អំពើឃោរឃៅ៖* ការខឹងមិនចេះទប់កំហឹងអាចនាំឲ្យកើតមានអំពើឃោរឃៅ ។ (លោកុប្បត្តិ ៤:៥-៨) មនុស្សឃោរឃៅមិនអាចយកខ្លួនធ្វើជាមិត្តនៃព្រះបានទេ ។ (ទំនុកដំកើង ១១:៥; សុភាសិត ២២:២៤, ២៥) គឺជាការខុសហើយបើយើងសងសឹកឬប្រព្រឹត្តអំពើអាក្រក់តបសងនឹងអំពើអាក្រក់ ដែលអ្នកឯទៀតបានប្រព្រឹត្តមកលើយើងនោះ ។—សុភាសិត ២៤:២៩; រ៉ូម ១២:១៧-២១

៥. *ការដាក់អំពើនិងមន្តអាគម៖* មនុស្សខ្លះអំពាវនាវហៅអំណាចនៃពួកវិញ្ញាណដើម្បីរកព្យាបាលរោគជម្ងឺ ។ អ្នកឯទៀតដាក់អំពើលើសត្រូវរបស់គេក្នុងបំណងធ្វើឲ្យគេឈឺឬទាំងធ្វើឲ្យគេស្លាប់ផង ។ អំណាចដែលនៅពីក្រោយការប្រព្រឹត្តទាំងនេះគឺសាតាំង ។ ដូច្នេះ គ្រីស្ទានមិនត្រូវមានចំណែកក្នុងការប្រព្រឹត្តទាំងនេះឡើយ ។ (ចោទិយកថា





១៨:៩-១៣) ការស្ថិតនៅឲ្យជិតព្រះយេហូវ៉ាគឺជាការការពារដ៏ល្អបំផុតពីអំពើដែលអ្នកឯទៀតដាក់មកលើយើង ។—សុភាសិត ១៨:១០

៦. *ការស្រវឹង៖* ការផឹកស្រា បៀយ៉ែ ឬភេសជ្ជៈមានជាតិស្រាតែបន្តិចបន្តួចគឺមិនមានអ្វីខុសទេ ។ (ទំនុកដំកើង ១០៤:១៥; ធីម៉ូថេទី១ ៥:២៣) ប៉ុន្តែ ការផឹកស្រាច្រើនហួសកំរិតនិងការស្រវឹង នោះគឺខុសហើយចំពោះព្រះនេត្រនៃព្រះ ។ (កូរិនថូសទី១ ៥:១១-១៣; ធីម៉ូថេទី១ ៣:៨) ការផឹកស្រាច្រើនហួសហេតុអាចនាំឲ្យខូចដល់សុខភាពអ្នកនិងធ្វើឲ្យមានការរំខានដុនដាបដល់គ្រួសារអ្នក ។ ហើយក៏អាចបណ្ដាលឲ្យអ្នកចុះញ៉មយ៉ាងឆាប់រហ័សក្នុងសេចក្ដីល្បួងឯទៀតផង ។—សុភាសិត ២៣:២០, ២១, ២៩-៣៥

៧. អ្នកដែលប្រព្រឹត្តអំពើដែលព្រះមានបន្ទូលប្រាប់ថាជាការអាក្រក់ នឹង«មិនបានគ្រងនគរព្រះ ទុកជាមរដកឡើយ» ។ (កាឡាទី ៥:១៩-២១) បើអ្នកពិតជាស្រឡាញ់ព្រះហើយចង់ផ្គាប់ព្រះហឫទ័យទ្រង់មែន នោះអ្នកអាចដោះខ្លួនចេញពីការប្រព្រឹត្តទាំងនេះ ។ (យ៉ូហានទី១ ៥:៣) សូមរៀនឲ្យបានដឹងហើយចេះស្អប់អ្វីដែលព្រះមានបន្ទូលប្រាប់ថាជាការអាក្រក់ ។ (រ៉ូម ១២:៩) សូមចូលរួបរួមជាមួយពួកអ្នកដែលមានទម្លាប់ល្អប្រពៃតាមព្រះហឫទ័យព្រះវិញ ។ (សុភាសិត ១៣:២០) មិត្តភក្តិគ្រីស្ទានដ៏មានការពិសោធគឺអាចធ្វើជាប្រភពមួយដែលផ្ដល់ជំនួយដល់អ្នកបាន ។ (យ៉ាកុប ៥:១៤) សំខាន់លើសគេបំផុតគឺសូមអ្នកពឹងផ្អែកលើជំនួយរបស់ព្រះតាមរយៈការអធិស្ឋាន ។—ភីលីព ៤:៦, ៧, ១៣